ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ...............................

# កំណត់ហេតុកិច្ចប្រជុំ
# ស្តីពីការរៀបចំរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧
# ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែមិថុនា ថ្ងៃទីដប់បី វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីការរៀបចំរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ដែលមានសមាសភាពចូលរួមសរុបចំនួន ២០រូប (ស្រី ០៤រូប) ។

គោលបំណងនៃកិច្ចប្រជុំគឺ តាមដានត្រួតពិនិត្យអំពីការប្រមូលទិន្នន័យ លទ្ធផលការងារ និងការរៀបចំរបាយការណ៍តាមក្រុមការងារអន្តរក្រសួង និងរាជធានី-ខេត្ត ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧ ។

**ជាកិច្ចចាប់ផ្តើម លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍អំពីការងារមួយចំនួនដែលបានអនុវត្តកន្លងមក៖**

- ការវាយតម្លៃលទ្ធផលការងារពាក់កណ្តាលអណត្តិទី១ បានផ្សព្វផ្សាយរួចហើយ តែនៅមិនទាន់មានការឆ្លើយតបមកវិញទេ ហើយយើងចាំបាច់ត្រូវរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តពាក់កណ្តាលអណត្តិទី២ទៀត (ជំនួយពី Winrock និង USAID) ដូចនេះក្រុមនីមួយៗត្រូវពិនិត្យមើលផែនការឲ្យបានច្បាស់លាស់ទើបអាចយកព័ត៌មានបាន ។
- យើងនឹងសហការជាមួយអង្គការ Winrock រៀបចំក្រុមតាមដានត្រួតពិនិត្យក្រុមការងារអន្តរក្រសួងដែលសមាសភាពយកនៅកន្លែងពួកគាត់តែម្តង តែស្ថិតនៅក្រោម គ.ជ.ប.ជ ។
- របាយការណ៍ក៏ពិបាកនឹងយកជាបានការណ៍ដែរបើក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និងអង្គការសង្គមស៊ីវិលមិនបានផ្ញើរមកគ្រប់នោះទេ ព្រោះវាជាបញ្ហាដែលនាំឲ្យបូករបាយការណ៍មិនបានគ្រប់ជ្រុងជ្រោយ និងមិនសុក្រឹត ហើយការផ្សព្វផ្សាយលទ្ធផលការងារក៏ដូចគ្នាដែរ គឺផ្ញើទៅបានលុះត្រាតែបូកសរុបបានគ្រប់សកម្មភាពទាំងអស់ ។
- កន្លងមក ទម្រង់របាយការណ៍មើលទៅមានលក្ខណៈដដែលៗ ដោយមិនបានរំលេចចេញនូវលទ្ធផលបានសព្វជ្រុងជ្រោយ ។

ជាកិច្ចបន្ត ក្រុមនីមួយៗបានផ្ញើសេចក្តីរាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ពីដើមឆ្នាំ២០១៧រហូតមកដល់ពេលនេះ ដែលមានដូចខាងក្រោម៖

១. ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ

- <u>បញ្ហាប្រឈម</u>៖ ក្រសួងកិច្ចការនារីថា មានការងារច្រើន និងកំពុងរង់ចាំប្រមូលរបាយការណ៍ ហើយ

អ្នកប្រមូលព័ត៌មានថា ក្រសួងពាក់ព័ន្ធបញ្ជូនមកយឺត និងពិបាកច្បិចយកចំណុចដែលចង់បាន ព្រោះក្រសួងពាក់ព័ន្ធមិនយល់ការងារ ។ ម្យ៉ាងទៀត សមាសភាពចូលរួមប្រជុំតែងតែផ្លាស់ប្តូរ ដែលនាំឲ្យតាមដានមិនជាប់ និងមិនយល់ ។

- លទ្ធផលការងារ៖ ក្រុមជំនួយកិច្ចការបានខិតខំប្រមូលព័ត៌មានពីគ្រប់ប្រភព និងបានចងក្រងព័ត៌មានឯកសារប្រជុំអន្តរជាតិដែលបានចូលរួម ។

២. ក្រុមជំនួយកិច្ចការយុត្តិធម៌

- បញ្ហាប្រឈម៖ បានទំនាក់ទំនងក្រសួងយុត្តិធម៌ជាប្រចាំ តែក្រសួងថា ជាប់រវល់ និងបានធ្វើលិខិតអញ្ជើញប្រជុំរួចហើយ តែមកទល់ពេលនេះនៅមិនទាន់មានកិច្ចប្រជុំទៀត ។
- លទ្ធផលការងារ៖ របាយការណ៍ពីក្រសួងយុត្តិធម៌ នៅមិនទាន់បានទេ ។
- សំណូមពរ៖ សូម លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ស្នើសុំ សម្តេចក្រឡាហោម បើកកិច្ចប្រជុំចង្អៀតថ្នាក់រដ្ឋមន្ត្រី ដើម្បីងាយស្រួលក្នុងការពិភាក្សា និងលើកពីបញ្ហាប្រឈម ។ និងចង់ធ្វើគោលការណ៍រួមឲ្យក្រសួងយុត្តិធម៌ចុះទៅធ្វើការងារជាមួយយើង ។

៣. ក្រុមជំនួយកិច្ចការអនុវត្តច្បាប់

- បញ្ហាប្រឈម៖ ផ្អែកតាមរបាយការណ៍រយៈពេល ២ឆ្នាំ ឃើញតែ ៦ខេត្តដែលបានអនុវត្តផ្ទាល់ រីឯខេត្តជាង១០ទៀតមិនបានអនុវត្តទេ ។ ការប្រមូលទិន្នន័យពីតុលាការគឺមិនបាន ។ ផែនការសកម្មភាពរបស់ក្រុមការងារបានរៀបចំ និងឆ្លងហើយ តែមិនទាន់បានចុះហត្ថលេខាជាផ្លូវការ ។
- លទ្ធផលការងារ៖ របាយការណ៍ប្រមូលបាន ៤ខែហើយ និងកំពុងបូកសរុបបន្ត ។ កំពុងរៀបចំគោលការណ៍ចុះទៅប្រមូលព័ត៌មានតាមបណ្តាខេត្ត (ជំហានទី១ គឺនៅខេត្តឆ្ងាយជាប់ព្រំដែន) ។

៤. ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ

- លទ្ធផលការងារ ៖ បានទទួលរបាយការណ៍ ៥ខែដើមឆ្នាំ និងកំពុងបូកបន្ត ។ បានស្រង់ទិន្នន័យជួយជនរងគ្រោះតាមរយៈស្ថានទូត ។ បានឲ្យក្រសួងសង្គមកិច្ចប្រមូលទិន្នន័យជនរងគ្រោះដែលទទួលបានសំណងទាំងក្នុងនិងក្រៅប្រព័ន្ធតុលាការ ការបញ្ជូនជនមាតុភូមិនិវត្តន៍ ។ និងបានជម្រុញឲ្យក្រុមការងារបើកកិច្ចប្រជុំអន្តរក្រសួង ។
- សំណូមពរ៖ បើក្រុមអនុវត្តច្បាប់ចុះទៅហើយ គួរក្រុមការពារជនរងគ្រោះកុំទៅ ព្រោះអាចរំខានគ្នា ។

៥. ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍

- បញ្ហាប្រឈម៖ ពិបាកទំនាក់ទំនងជាមួយក្រសួងការងារ ពីមុនមានទំនាក់ទំនងល្អ តែឥឡូវទំនាក់ទំនងមិនសូវល្អ ក្រសួងចេះតែពន្យាពេល និងមិនបានអញ្ជើញក្រុមជំនួយកិច្ចការចូលរួមប្រជុំ ។
- លទ្ធផលការងារ៖ នឹងបញ្ចប់របាយការណ៍នៅប្រមាណ ១០ថ្ងៃទៀត ។ បានចងក្រងព័ត៌មានផ្សព្វផ្សាយជូនថ្នាក់ដឹកនាំ និងរក្សាទុកជាឯកសារ ។

៦. ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់

- បញ្ហាប្រឈម៖ បានទំនាក់ទំនងក្រសួងអប់រំ តែមិនបានទទួលទិន្នន័យទេ
- លទ្ធផលការងារ៖ បានប្រមូលព័ត៌មានតាមរយៈតេឡេក្រាម និងរក្សាទុកជាឯកសារ ព្រមទាំងបានផ្ទៀងផ្ទាត់មើលថាពិតឬមិនពិត បើមានកន្លែងលើសឬខ្វះចន្លោះនឹងទំនាក់ទំនងសួរនាំ ។

៧. លេខាធិការដ្ឋានរដ្ឋបាលសរុប

- បានសម្របសម្រួល និងកែសមាសភាព គ.រ.ប.ជ/គ.ខ.ប.ជ ចំនួន ១៣រាជធានី-ខេត្ត និងក្រុមការងារចំនួន ២ ។

- បានបញ្ជូនលិខិតជំរុញប្រមូលរបាយការណ៍តាមបណ្តារាជធានី-ខេត្ត ។
- បានជំរុញឲ្យបណ្តាខេត្តជាប់ព្រំដែនប្រមូលទិន្នន័យទេសន្តរប្រវេសន៍តាមច្រកចេញ-ចូល ។
- បានសម្របសម្រួលប្រមូលរបាយការណ៍ខែឧសភា បាន ២០ខេត្ត ។
- ក្រសួងសង្គមកិច្ចបានផ្ញើរបាយការណ៍មកបាន ៣ខែ តែក្រសួងផ្សេងគ្មាន ។

ជាទីបញ្ចប់ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍បូកសរុប និងផ្តល់អនុសាសន៍ណែនាំអំពីការមួយចំនួន ដូចខាងក្រោម៖

- ចំពោះ ក្រុមជំនួយកិច្ចការយុត្តិធម៌៖ បើគេមិនផ្ញើរទិន្នន័យមក យើងគួរចុះទៅរួមគ្នាជាមួយក្រុមក្រសួងយុត្តិធម៌ តែបេសកកម្មត្រូវចេញរៀងខ្លួន ។ ចំពោះការប្រមូលទិន្នន័យគួរសួរយោបល់ **ឯកឧត្តម អ៊ិត រ៉ាឌី** ថាតើធ្វើដូចម្តេចទើបយកទិន្នន័យបាន ។
- ចំពោះ ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖ បើចុះទៅត្រូវផ្តោតជាលក្ខណៈតំបន់ និងត្រូវដឹងអ្វីដែលយើងចង់បានមុននឹងទៅ ។
- យើងត្រូវមើលគេធ្វើផង និងធ្វើខ្លួនឯងផង គឺសម្របសម្រួល តាមដាន និងជំរុញ ដើម្បីប្រមូលផ្តុំគ្រប់ព័ត៌មាន និងសកម្មភាពឲ្យបានសព្វជ្រុងជ្រោយ ។
- ការដោះស្រាយនានាត្រូវធ្វើតាមតួនាទីភារកិច្ច ដើម្បីកុំឲ្យជាន់ការងាររបស់គេ ។
- បើយកព័ត៌មានពីក្រសួងមិនបាន គួរប្រមូលពីគ្រប់ប្រភព រួចផ្ញើទៅក្រសួងដោយដាក់ប្រភពព័ត៌មានច្បាស់លាស់ ដើម្បីឲ្យក្រសួងឆ្លើយតបថាគេឯកភាពឬអត់ និងកំណត់ពេលនៃការឆ្លើយតប ។
- ក្រុមជំរុញ និងប្រមូលរបាយការណ៍រាជធានី-ខេត្ត ត្រូវជំរុញ និងបញ្ជាក់ឲ្យច្បាស់ថាមានឬអត់ ។
- សូមឲ្យក្រុមនីមួយៗបូកសរុបលទ្ធផលការងារចំពោះមុខសញ្ញារៀងៗខ្លួន និងចងក្រងជាប្រព័ន្ធទិន្នន័យ ហើយក្រុមនីមួយៗត្រូវសម្រួលរបាយការណ៍នោះសិន មុននឹងយកទៅឲ្យអ្នកបូកសរុប ។
- បើមិនបានជួបប្រជុំ ត្រូវដាក់ក្នុងរបាយការណ៍ ដើម្បីរាយការណ៍នៅពេលប្រជុំធំ ។
- ការធ្វើផែនការសកម្មភាព ត្រូវស្របតាមយុទ្ធសាស្ត្រទាំង៤ និងពិនិត្យមើលថាត្រូវជំរុញអ្វី ឬកាត់បន្ថយអ្វី និងត្រូវធ្វើឲ្យហើយដើម្បីដាក់ប្រជុំជាសិក្ខាសាលា រួចសុំយោបល់ថ្នាក់ដឹកនាំដើម្បីបោះពុម្ពផ្សព្វផ្សាយ ។
- ពីពេលនេះរហូតដល់ចុងខែនេះត្រូវជំរុញរបាយការណ៍ឆមាសទី១សិន ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧
**អ្នកធ្វើកំណត់ហេតុ**

គោរពជូន លោកជំទាវ
អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។
ភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧
**ប្រធានលេខាធិការដ្ឋាន**

**ឧត្តមសេនីយ៍ទោ. គង់ ពុទ្ធី**

**សមាសភាពចូលរួមកិច្ចប្រជុំ**
**ពីការរៀបចំរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧**
**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧**
**សរុបចំនួន ២០ រូប (ស្រី ០៤រូប)**

| | | | |
|---|---|---|---|
| ១ - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ | |
| ២ - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| ៣ - ឯកឧត្តម ឧ.ឯក | ឃឹម វិរៈ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៤ - ឯកឧត្តម ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៥ - លោកជំទាវ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៦ - លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៧ - ឯកឧត្តម ឧ.ឯក | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៨ - ឯកឧត្តម ឧ.ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៩ - ឧត្តមសេនីយ៍ទោ | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ១០ - លោក | តែ សុថារ៉េត | ប្រធាននាយកដ្ឋានស្តីទី | គ.ជ.ប.ជ |
| ១១ - វរសេនីយ៍ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ១២ - លោក | ប៉ុណ្ណ ចន្ថា | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ១៣ - វរសេនីយ៍ឯក | កែវ ផល្លា | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៤ - វរសេនីយ៍ឯក | សាង រំដោះ | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៥ - វរសេនីយ៍ទោ | ឃឹម សំណាង | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៦ - វរសេនីយ៍ត្រី | អ៊ុន សុខជា | នាយការិយាល័យ | គ.ជ.ប.ជ |
| ១៧ - វរសេនីយ៍ត្រី | ហ៊ី រតនៈ | អនុប្រធានការិយាល័យ | គ.ជ.ប.ជ |
| ១៨ - អនុសេនីយ៍ត្រី | ជុំ សេន | មន្ត្រី | គ.ជ.ប.ជ |
| ១៩ - អនុសេនីយ៍ត្រី | សួន ផៃ | មន្ត្រី | គ.ជ.ប.ជ |
| ២០ - អនុសេនីយ៍ត្រី | ច័ន្ទ បញ្ញា | មន្ត្រី | គ.ជ.ប.ជ |